# ពោធិព្រឹក្ស

លេខ ៧០ ខែ មេសា គ.ស.២០២២

N° 70 Mois d'Avril 2022




Pothiproeuk

Le vénérable NGIN Phène a fait imprimé la journée du "23 OCTOBRE 91" sur des centaines de shirt pour distribuer gracieuseent aux Cambodgiens

ព្រះអង្គគ្រូ ងិន ភេន ឲ្យបោះពុម្ព ថ្ងៃ ២៣ តុលា ៩១ នៅលើអាវយឺតច្រើនរាប់រយ ទុកចែកជាធម្មទានជូនដល់បងប្អូនខ្មែរ

**ព្រឹត្តិប័ត្រ សមាគម ឧបត្ថម្ភពុទ្ធសាសនាខ្មែរ វត្តពោធិវង្ស**

**BULLETIN DE L'ASSOCIATION POUR LE SOUTIEN DU BOUDDHISME KHMER**

SOMMAIRE


**Pages**

**Explication sur la photo de la couverture** **3**

**Nouvelles - ដំណឹង :**

- កាន់បិណ្ឌ - Kan Ben
- ភ្ជុំបិណ្ឌ - Pchum Ben
- បុណ្យចេញវស្សា - Sortie de la retraite des moines
- កឋិនទាន - Kathina 6
- មាឃបូជា - Māga Pujā 7
- Les Thngay- Bon-Soel ou jours saints - ថ្ងៃសីល **9**

Textes - អត្ថបទ :

- ស្រក់ទឹកភ្នែកតែមិនយំ ដោយ ភិក្ខុ ជិន កេន ឥន្ទប្បញ្ញោ **10**
- រៀបចំ ជីវភាព តាមសណ្ដាប់ធ្នាប់ និង គុណធម៌ ទាំង ៦ ដោយ នេត្រ សេដ្ឋា **11**
- កុំអង្គុយ ក្នុងចង្អេរ ហើយលើកខ្លួន (ក្រុម/បក្ស/ពួកឯង) ដោយ នេត្រ សេដ្ឋា **12**

Document - ឯកសារ :

បូជនីយដ្ឋាន ព្រះសក្យមុនីចេតិយនៅភ្នំឧដុង្គ **13**

Information - ពត៌មាន :

Compte rendu de la diaspora khmère **16**

# Explication sur la photo de la couverture

Manifestation pour le rappel sur « les accords de paix du 23 Octobre 1991 »
Le samedi 23 Octobre 2021, la marche de la Place de la République jusqu'à la Place de la Nation




**ALLOCUTION DE M. FRANÇOIS MITTERRAND, PRESIDENT DE LA REPUBLIQUE, SUR L'ACTION DE LA FRANCE ET DE L'INDONESIE DANS LE REGLEMENT DU CONFLIT DU CAMBODGE ET SUR LE ROLE JOUE PAR L'ONU DANS LE REGLEMENT DES CONFLITS REGIONAUX, PARIS, LE 23 OCTOBRE 1991.**

23 octobre 1991 - Seul le prononcé fait foi

Monseigneur,
- Monsieur le secrétaire général,
- Madame et messieurs les ministres,
- Mesdames, messieurs,

- Au nom de la France, je vous souhaite la bienvenue. Et je déclare ouverte la conférence de Paris sur le Cambodge. Nous sommes aujourd'hui réunis, pour conclure un accord de paix sur le Cambodge et, par là-même, tourner une page sombre de l'histoire de ce pays, non seulement de ce pays mais aussi de toute l'Asie du Sud-Est, région du monde où, pour la première fois depuis cinquante ans, les armes vont se taire.

- Certains d'entre vous se souviendront sans doute que c'est dans cette même salle que s'est tenu, il y a bientôt un an, le sommet de la Conférence sur la sécurité et la coopération en Europe au cours duquel fut proclamée la fin de la guerre froide et adoptée la Charte de Paris. Je vois dans cette coïncidence un signe encourageant puisqu'après l'Europe c'est en Asie que nous nous employons à jeter les bases d'un nouvel ordre de paix et de coopération.\

Lorsqu'en septembre 1988, à New York, à la tribune de l'Assemblée générale de l'organisation des Nations unies, j'avais invité les parties concernées par le conflit du Cambodge à se rencontrer à Paris, j'étais animé, comme vous tous, par le souci de voir s'achever le long calvaire que connaissait ce pays depuis 1970. J'avais aussi la conviction que seul un règlement politique d'ensemble était en mesure de mettre fin à la tragédie de ce peuple pris dans la tourmente de la deuxième guerre d'Indochine, puis livré à un régime impitoyable entre tous.

- L'action tenace de la France et de l'Indonésie à ses côtés en faveur de la paix est aujourd'hui couronnée de succès. En juillet 1989, nous avions commencé d'espérer. Mais des dissensions entre puissances de la région et des querelles entre Cambodgiens nous avaient empêché d'aboutir. Cette rencontre de 1989 avait cependant permis à tous de se réunir pour la première fois autour d'une même table et de définir les axes d'un règlement politique, après tout, ces axes sont ceux qui ont fini par s'imposer. On le constate dans d'autres conflits : établir un cadre de travail, se mettre d'accord sur les prémices d'une solution, c'est déjà faire la moitié du chemin. L'accord que nous allons signer tout à l'heure est l'œuvre des pays de la région, et d'abord de l'Association des Nations de l'Asie du Sud-Est, qui ont veillé pendant de longues années à ce que ce conflit ne fut pas oublié. Elle est l'œuvre aussi des voisins immédiats du Cambodge et de pays qui ont surmonté le découragement en préconisant l'intervention des Nations unies.

- Cette idée a conduit aux travaux qui ont été menés depuis janvier 1990 par les cinq membres permanents du Conseil de sécurité. Ceux-ci n'entendaient pas dicter au Cambodge, bien entendu, les termes d'un accord mais, en se fondant sur les responsabilités qui sont les leurs au titre de la Charte, ils ont voulu user de leur influence pour contribuer à la recherche d'un règlement de paix. L'association, très étroite, à ces travaux, du secrétaire général des Nations unies, que je salue, et de ses collaborateurs, ont confirmé une nouvelle fois le

rôle déterminant joué par les Nations unies au cours des dernières années pour le règlement de nombre de conflits qu'il est convenu par euphémisme diplomatique de dénommer "régionaux". Mais rien n'aurait pu se faire sans la volonté des Cambodgiens eux-mêmes de surmonter les haines, les rancunes, de se réconcilier, retrouvant en cela l'esprit de l'ancienne devise khmère "le Cambodge s'aide lui-même".

- J'entends également rendre ici hommage au Prince Sihanouk qui a su, au moment opportun, remplir le rôle historique que les circonstances exigeaient et que lui seul, je le pense, pouvait assumer. Son retour à Phnom-Penh, le mois prochain, sera le symbole de la renaissance du Cambodge, de la réconciliation de tous les Cambodgiens. Et tous, ici présents, méritent qu'on leur dise qu'ils ont agi, à la fois dans l'intérêt de leur peuple et dans l'intérêt de la paix dans le monde. Ce soir, une nouvelle page de l'histoire du Cambodge commencera d'être écrite.\

Il appartient désormais aux Nations unies d'organiser une opération d'une envergure sans précédent dans leurs annales. Une autorité provisoire dotée d'une composante civile et militaire va veiller au maintien de la paix, de la sécurité et de la stabilité du Cambodge pendant la période transitoire et garantira durant ce temps la neutralité politique, indispensable à la tenue prochaine d'élections libres, démocratiques et à la réconciliation nationale. Les accords auxquels nous avons abouti ne laissent dans l'ombre aucune des dimensions du conflit. Ils traitent de façon précise de la souveraineté, de l'indépendance, de l'intégrité territoriale, de la neutralité et de l'unité nationale du Cambodge, ainsi que de la démobilisation et du désarmement, du retour des réfugiés et des personnes déplacées. Pour tenir compte de la spécificité du problème cambodgien et de tout ce qui s'y est accompli, ces accords contiennent également des dispositions contraignantes en matière de respect des droits de l'homme, ce qui n'a de précédent dans aucun autre accord international. En signant ce document ce soir, nous savons que notre rôle n'est pas terminé. Des difficultés subsistent et subsisteront et nous craignons en particulier que les conditions de retour des 350000 réfugiés ne s'effectuent pas toujours dans des conditions de sécurité, de liberté et de dignité compatibles avec les engagements pris par tous.

- C'est pourquoi, je lance ici un appel solennel à tous les responsables, pour qu'ils reconnaissent au seul Haut Commissaire pour les réfugiés des Nations unies la responsabilité du rapatriement et de la réinstallation des personnes déplacées. Il faut que tous le comprennent et l'admettent. Les opérations que les Nations unies engageront au Cambodge seront d'une ampleur jamais atteinte pour et par la communauté internationale. Mais c'est le prix de la paix. Et il sera, croyez-moi, moins élevé que celui de la poursuite de la guerre et de la misère d'un peuple.

- A compter d'aujourd'hui, le peuple khmer va retrouver la pleine maîtrise de son destin. Il n'appartient qu'à lui de déterminer son avenir politique. Mais personne n'acceptera qu'il connaisse de nouvelles souffrances. Les Cambodgiens, je crois pouvoir le dire en votre nom, aspirent à la paix, de toutes leurs forces. Ce qui exige l'abandon de tout esprit de revanche qui serait aussi dangereux que l'oubli de l'histoire et de ses drames.
- A tous les Cambodgiens, je souhaite bonne chance et longue vie, dans leur peuple, réunis, et dans leur pays, libres. L'Asie comme le reste du monde change. Elle connait depuis plusieurs années une croissance économique exceptionnelle. Les principes démocratiques y gagnent progressivement du terrain et la fin de la guerre du Cambodge ouvre dans cette région de l'Asie du Sud-Est des perspectives prometteuses fondées sur la croissance et les valeurs communes du progrès et de la démocratie. Les frontières vont enfin s'ouvrir pour le pays khmer. Le Cambodge va reprendre sa place dans le monde, comme ce fut le cas le mois dernier, à l'Assemblée générale des Nations unies. En faisant ce choix, le Cambodge a fait aussi celui de la démocratie. Et je salue l'engagement solennel pris par tous les membres du Conseil national suprême en faveur d'une démocratie pluraliste. Rien ne pouvait mieux inciter la communauté internationale et ses institutions financières ainsi que les organisations spécialisées des Nations unies à fournir à ce pays, à votre pays, les moyens de sa reconstruction et de son développement.\

Qu'on me permette, puisque vous vous réunissez à Paris, et que j'exerce la charge suprême de la France, de saluer aussi la reprise des relations entre le Cambodge et mon pays. Comment n'en serai-je pas très heureux, en raison des liens si forts qui nous unissent et qui n'ont jamais été rompus ? Nos sentiments pour le Cambodge n'ont jamais décliné. Je crois pouvoir dire que notre façon d'agir montre que ni l'aide ni les sentiments n'ont été taris. Et nous sommes prêts à continuer, en particulier à accueillir dans nos grandes écoles, nos universités, nos laboratoires ceux qui sont appelés à diriger le Cambodge de demain.

C'est une invitation très amicale. J'encourage aussi très vivement tous nos chefs d'entreprise, nos hommes d'affaires, nos banquiers et les autres, ingénieurs, techniciens à reprendre le chemin du Cambodge. Je dis cela au nom de la France, parce que c'est elle que j'engage, mais je suis sûr que les paroles que je prononce ici pourraient être dites aussi bien par les responsables de nombreux autres pays.

- Je veux maintenant, pour conclure, répéter mes vœux les plus ardents pour la renaissance du Cambodge, mes vœux pour ce peuple, votre peuple, pour la paix, pour la démocratie. Il y a droit, le peuple khmer. Et nous, membres de la Conférence de Paris, ici assemblés, nous entendons en rester les garants, quoi qu'il advienne. C'est une sorte d'engagement auquel nous souscrivons puisque nous avons l'honneur d'être auprès de vous pour signifier une ère nouvelle.\




Le texte intégral des accords signés à Paris le 23 octobre 1991 par les États participant à la Conférence (l'Australie, Brunei Darussalam, le Cambodge, le Canada, la République populaire de Chine, les Etats-Unis d'Amérique, la République française, la République de l'Inde, la République d'Indonésie, le Japon, la République démocratique populaire lao, la Malaisie, la République des Philippines, le Royaume-Uni de Grande Bretagne et d'Irlande du Nord, la République de Singapour, le Royaume de Thaïlande, l'Union des Républiques socialistes soviétiques, la République socialiste du Vietnam et la République fédérale socialiste de Yougoslavie.).

Les trois points principaux adoptés par la conférence :

- Accord pour un règlement politique global du conflit au Cambodge,
- Accord relatif à la souveraineté, l'indépendance, l'intégrité et l'inviolabilité territoriales, la neutralité et l'unité nationale du Cambodge,
- Déclaration sur le relèvement et la reconstruction du Cambodge. (A/46/608-S/23177, 30 octobre 1991). (Voir : « *Les Nations-Unis et le Cambodge-1991-1995* », avec une introduction de Boutros Boutros Ghali, Secrétaire Général de l'Organisation des Nations-Unies, Publié par les Nations-Unies, New-York, N.Y. 10017, 1995).

## Un échec cuisant » : 30 ans après les accords de paix, le Cambodge s'enfonce dans la dictature

Le 23 octobre 1991, épuisées par deux décennies de guerre civile, les forces politiques cambodgiennes signent les accords de Paris, entérinant un processus de paix sous l'égide de l'ONU. Trente ans plus tard, le Cambodge vit sous un régime autoritaire dirigé depuis plus de trois décennies par le premier ministre. LACROIX Dorian Malovic, le 23/10/2021

## **Nouvelles - ដំណឹង**



### Du mercredi 22 septembre au mercredi 6 octobre 2021

### ចាប់ពីថ្ងៃពុធ ទី២២ ខែកញ្ញា ដល់ ថ្ងៃពុធ ទី៦ តុលា ឆ្នាំ២០២១

### Kan Ben - កាន់បិណ្ឌ

Différentes familles se déplacent à tour de rôle à la pagode lors de chacune de ces journées.

Dans un geste de bienveillance, les meilleurs plats sont préparés pour contenter les esprits des ancêtres. Des bâtonnets d’encens consumés et les plats sont offerts aux moines pour les transmettre aux esprits de leurs ancêtres a travers les prières. La liste des noms est déclamée puis brûler par le bonze. Ce rituel est destiné à prévenir les âmes errantes du lieu où se sont réunis les proches.

Kan Ben se finit avec Pchum Ben qui est une des plus grandes fêtes khmères. Les familles se rassemblent au sein de la pagode.

### Dimanche 3 octobre 2021 - ថ្ងៃអាទិត្យ ៣ តុលា ២០២១

#### Pchum Ben - ភ្ជុំបិណ្ឌ

C’est un moment pour les Cambodgiens de commémorer, de réunir et pour exprimer leurs affections et reconnaissances envers leurs ancêtres. A travers les offrandes aux bonzes et les prières, les fidèles apaisent leurs misères qui sont restées bloquer dans le monde des esprits et les ramènent dans le chemin de la réincarnation.

Une fois les ancêtres réincarnés, ils pourront accumuler par eux-mêmes des mérites pour un meilleur Karma qui leur permettra d’atteindre un esprit imprégné de paix intérieure

### Dimanche 21 octobre 2021 - ថ្ងៃអាទិត្យ ២១ តុលា ២០២១

#### Sortie de retraite des moines - បុណ្យចេញវស្សា

A la fin de la période de retraite des bonzes, les bonzes se réunissent pour confesser leurs péchés et les fidèles apportent des offrandes.

### Dimanche 24 octobre 2021 – ថ្ងៃអាទិត្យ ២៤ តុលា ២០២១

#### Kathina -កឋិនទាន ២១ ២៤

Kathen est une cérémonie d’offrande des robes aux bonzes, célébrée à la sortie de Vossa.




Dimanche 13 février 2022 – ថ្ងៃអាទិត្យ ១៣ កុម្ភៈ ២០២២

Māga Pujā - មាឃបូជា

Selon la tradition bouddhiste, il y a environ 2500 ans, sept ans après que Bouddha ait commencé son enseignement, 1250 disciples se rassemblèrent spontanément pour écouter son sermon. Bouddha ordonna à ses disciples, faisant ainsi d'eux les premiers moines, de diffuser les préceptes du bouddhisme. 45 ans plus tard, sous la même pleine lune du troisième mois lunaire, Bouddha fit un sermon annonçant sa mort.



De gauche à droite : Vénérable NGIN Phèn et Vénérable LAM Siek









# Les Thngay- Bon-Soel ou jours saints.

Les jours de Thngay soel qui reviennent quatre fois par mois et qui sont tous célébrés de la même manière. Ces jours-là, pour les religieux, les prières sont plus nombreuses, les heures de méditation sont plus longues,le silence dans le monastère est plus absolu et les travaux dont suspendus.

... Les femmes surtout – dès 7 heures du matin, se rendent au monastère avec des vivres qu'elles offrent aux religieux, des fleurs et des baguettes odoriférantes qu'elles présentent au Buddha après s'être inclinés et avoir prié, assis à terre et les mains jointes. Le matin principalement, l'autel est allumé et la fumée des baguettes odoriférantes l'envelppe d'une nuée parfumée.

...Dès 7 heures du matin, l'Achar, qui est le maître ordinaire des cérémonies, convoque les religieux, soit au temple, soit dans la salle des conférences. Quand ils y ont pris place, un peu en avant et à droite de l'autel, il les salue trois fois au no des fidèles présents, et les invite à dire les prières ordinaires. Dans le silence de la salle, alors que toute l'assistance a les mains jointes à hauteur du visage, les religieux disent de leur voix nasillarde la salutation au Buddha.

...Les fidèles saluent en levant les mains et s'inclinent.

... Alors l'Achar, joignant les mains à la hauteur de son front, murmure l'invitation aux divinités des huits points cardinaux et intercardinaux. "*CAMBODGE. FÊTES CIVILES ET RELIGIEUSES*" PAR ADHÉMARD LECLÈ. PARIS IMPRIMERIE NATIONALE 1917.





Thngay- Bon-Soel ou jours saints à la Pagode Bodhivansa

ស្រក់ទឹកភ្នែកតែមិនយំ

*ជាហេតុកើតឡើងនៅក្នុងព្រះរាជាណាចក្រកម្ពុជា នា ខែវិច្ឆិកា ឆ្នាំ២០២១*

# កម្មបណ្ដាល

*កម្មបណ្ដាលឲ្យទឹកភ្នែកថៅហូរ    រន្ធត់អាសូរលោកតាខ្លាំងណាស់*
*លោកតាបានសាងកម្មធ្ងន់ក្រៃក្រាស់    លើខ្មែរច្រើនណាស់ពេញកម្ពុជា ។*

*ឲ្យយួន ចិនចូលមកអភិវឌ្ឍ    កាត់ដីសម្បទានទៅឲ្យពួកវា*
*រាប់ពាន់ម៉ឺន សែន រាប់ពាន់ហិកតារ    សម្បត្តិខេមរាខ្ទិចខ្ទីអស់ហើយ ។*

*ខេត្តខ្មែរបីបួន ខេត្តឡាវបីបួន    រួមនឹងខេត្តយួនបួនប្រាំអ្នកអើយ*
*មណ្ឌលត្រីកោណបានកើតព្រមហើយ    ឱ!ខ្មែរ ឡាវអើយ យួនអ្នកកាន់កាប់ ។*

*ខេត្តកោះកុង និងក្រុងកំពង់សោម    ក្រុងរាមរួបរួម កំពតឲ្យធាប់*
*ប្រគល់ឲ្យចិនរៀបចំកាន់កាប់    សាងក្រុងប្រញាប់តាមច្បាប់ចិនផង ។*

*បែរខ្នងឲ្យអាមេរិក អឺរ៉ុប    ដៀមដាមមិនឈប់និយាយឌឺដង*
*ចោទគេរំលោភអធិបតេយ្យផង    នាំឲ្យសៅហ្មងរឿងកើតមិនឈប់ ។*

*កម្មនេះឲ្យផលដល់កូន ដល់ចៅ    រងទុក្ខក្ដួលក្ដៅទាំងថ្ងៃទាំងយប់*
*ស្លាប់ទៅឥតវិចី គ្មានអ្វីជួយទប់    រងទុក្ខគ្រប់មុខ កម្មលោកតាសាង ។*

*ភិក្ខុ ងិន ភេន ឥន្ទប្បញ្ញោ*

# រៀបចំ ជីវភាព តាមសណ្តាប់ធ្នាប់ និង គុណធម៌ ទាំង ៦

១ - ដើម្បី ធ្វើឲ្យពិភព លោក          បានជួបជ័យជោគ - សន្តិភាព
ប្រទេស ទាំងអស់ទោះ ខ្ពស់ - ទាប          ធ្វើតាម របៀប -សណ្តាប់ធ្នាប់ ។
២ - ដើម្បីប្រទេស ស្គាល់ សណ្តាប់          គ្រួសារ ត្រូវ ស្តាប់ តាមបង្គាប់
ទទួល យល់ព្រម យ៉ាង គួរគាប់          ស៊ីវិល និង ទ័ព ធ្វើចំរុះ ។
៣ - ដើម្បី គ្រួសារ ស្គាល់ របៀប          រៀបរយ - សុភាព, ល្អ ឬ ខុស
ត្រូវមនុស្ស ម្នាក់ៗ ស្រី ឬ ប្រុស          កែ - កុន មើលធ្លុះ ចិត្តខ្លួនឯង ។
៤ - ផ្សាំងចិត្ត គំនិត ឲ្យបានច្បាស់          ត្រូវហ៊ាន ប្តូរ ផ្លាស់ គ្មាន ខ្លាចក្រែង
ធ្វើល្អ, តាមធម៌ យ៉ាងជាក់ស្តែង          ស្តាប់ពាក្យ ចង់ចែង, ប្តូរកិរិយា ។
៥ -ខិតខំ ស្វែងរកការ ចេះដឹង          ព្យាយាម ប្រិតប្រឹង ប្រើ "បញ្ញា"
យ៉ាងឆ្លាត វាងវៃ, ខំសិក្សា          ប្រកប កិច្ចការ លុះសម្រេច ។
៦ - ចិត្តឲ្យ "ក្លាហាន", ឲ្យ ស្វាហាប់          កុំខ្ជិល ខុសច្បាប់, ខុសក្បួន ក្បាច់
ទោះពិបាក - ឈឺ - នឿយមិនដាច់          ឈ្នះ ជាចាំបាច់, ជា គោលដៅ ។
៧ - ត្រូវចេះស្រឡាញ់ ដោយ "មនុស្សធម៌"          អាណិត, ញាប់ញ័រ នឹងអ្នកក្រៅ
ជួយ ជន ទន់ខ្សោយ យ៉ាងកក់ក្តៅ          ប្រដែប្រដៅ ដោយ សុទ្ធចិត្ត ។
៨- យក "យុត្តិធម៌" ជាអាវុធ          ដើម្បី ប្រយុទ្ធ រក្សាសិទ្ធ
រក្សា នូវភាព អព្យាក្រឹត          ឥតលួច បង្ខិត ឬ បន្ទំ ។
៩- "មត្តញ្ញុតា" * ចេះ អោន អត់          មិន ខឹង, អំណត់ ជា ឧត្តម
បំភ្លេច ទោសភ័យ គ្មាន ក្រៀមក្រំ          មិនប្រឹង ប្រៀបខំ សងសឹកឡើយ ។
១០ - "អតិសេដ្ឋភាព" ** គួរ រក្សា          ក្នុងដួង ចិន្តា ជាចម្លើយ
ជា ក្តី សង្ឃឹម ឲ្យបាន ស្បើយ          ទើបបានកៀកកើយភាពខ្ពង់ខ្ពស់ ។ ៚

នេត្រ សេដ្ឋា
១១ មេសា ២០២០

* មត្តញ្ញុតា : ការចេះទប់ចិត្ត, ចេះអត់អោនទោស

** អតិសេដ្ឋភាព : ភាពហួសវិស័យមនុស្សគិត (Spiritualité)

កំណាព្យនេះ ហូរចេញពីពាក្យទូន្មាន នៃ ទស្សនវិទូ កុង ស៊ូ (Confucius)
កំណើត ឆ្នាំ ៥៥១, ស្លាប់ឆ្នាំ ៤៧៩ មុន គ.ស

# កុំអន្ទុយ ក្អួចចង្អោរ ហើយលើកខ្លួន ( ក្រុម/បក្ស/ពួកឯង )

១- សុភាសិត មួយចង់ចែងថា
កុំលើកអាត្មា ឬក្រុមឯង
បើនៅ អង្គុយយ៉ាង ខែង វែង
ក្អុងត្បាល់, កញ្ជ្រែងឬ កញ្ចេ ។
២- ពាក្យនេះ អាចឲ្យយើង ឃើញ យល់
ជា គ្មានបុគ្គលម្នាក់ណា ទេ
អាចលើក ខ្លួន ខ្ពស់ ទាំងចង្អេរ
បើសិនគ្មានគេ ជួយ ទប់ទាំង ។
៣- មនុស្ស ខ្វះស្មាន ថា ខ្លួន ពូកែ
អួតអាង គ្មានល្ហែ, គ្មានរលាំង
យកកុហក - ភូត ជា រនាំង
បិតជា ជញ្ជាំង តាម ល្បិចខ្លួន ។
៤- ពុំនោះ មនុស្សនេះ ដើរទាក់ទង
ប្រមូលចូលស៊ង, អូស ចូល អួន
ផ្តុំ ប្រជុំជន មិន នឹមនួន
ទើបប្រកាស ខ្លួន ថា ជា មេ ។
៥- បើ មេមនុស្ស ល្អវា មិន ស្អី
តែមេអប្រីយ, នាំ ខ្មាស់ គេ
មេ កំសាក ញី គេថែម ជេរ
គ្មាន ក្លាហានទេ, គេចជានិច្ច ។
៦- បោកប្រាស មនុស្ស ល្ងង់ មិនប្រសើរ
ឲ្យគេ ហៃ អើ, ហេរ រវិច
ជនភ្លើ នឹង ជឿ នូវពាក្យពេចន៍
មុខជា លុងលិច ទាំង អស់គ្នា ។
៧- ដើម្បី ឲ្យគេកោត, គេខ្លាច
មនុស្ស នេះ នឹងអាច ប្រើវិជ្ជា
ផ្ចិនភ្នែក, ផ្ទុំត្រចៀក គ្រប់ពេលា
ភូតភរជនា, លួចបន្ទំ ។
៨- ជន អើយ កុំជឿ, កុំចាញ់បោក
ក្រែង លោ វាសោក, ស្តាយ ក្រៀមក្រំ
គិតពិចារណា ឲ្យសក្តិ សម
កុំឲ្យប្រទ្បំ រើស មេ ខុស ។
៩-មនុស្សល្អ, ត្រឹមត្រូវ មិនចាំបាច់
បំភ័ន្ត ខុសក្បាច់, ប៉ាំង កំហុស
កិរិយា ត្រង់ ដូចកញ្ចក់ច្ចុះ
គេ ឯង ចូលចុះ ជួយគាំទ្រ ។
១០-មនុស្សល្អ, មិនចាំ លើកខ្លួន ឯង
គេជូន តំណែង, គេសាទរ
គេ ស្រែក ជយោ, ឮ ខ្ទរខ្ទរ
មនុស្ស ទាំង នគរ ទទួលស្គាល់ ។៚

នេត្រ សេដ្ឋា

១៦ មេសា ២០២០

កំណត់ : យោងទៅតាមខែត្រ ស្រុក ឬ តំបន់ ក្នុងប្រទេស, សុភាសិតនេះ អាចប្តូរ
ពាក្យ "ចង្អេរ", ទៅ ជា ត្បាល់ ឬ កញ្ជ្រែង ឬ កញ្ចេរ ឬ កញ្ជើ ឬល្អី ។ល។
សុភាសិតខាងលើនេះ មានន័យប្រហាក់ ប្រហែល នឹង សុភាសិត មួយទៀត
"គោគេមិនអួត, អួតតែគោឯង " ។

# បូជនីយដ្ឋាន ព្រះសក្យមុនីចេតិយនៅ ភ្នំឧដុង្គ

*បូជា [១] =ការថ្វាយឬជូនវត្ថុអ្វីៗ ចំពោះបូជនីយបុគ្គល ។*

*បូជនីយ:=ដែលគួរបូជា ។*

*បូជនីយបុគ្គល (បូជ:នីយ:បុក-គល់) បុគ្គលដែលគួរគេបូជា : ព្រះពុទ្ធ, ព្រះអរហន្ត, អ្នកមានសីល, ព្រះមហាក្សត្រ, មាតាបិតា, គ្រូអាចារ្យ ... ជាបូជនីយបុគ្គល ។*

*បូជនីយដ្ឋាន=ទីកន្លែងដែលគួរគេបូជា ។*

*ក្រោយពីមានការរាំងស្ងួតជាច្រើនឆ្នាំនិងចម្បាំងលុកលុយពីសៀម និងយួនមិនចេះចប់, នាសតវត្ស ទី១៥ ទីក្រុងអង្គរត្រូវបានបោះបង់ចោល ។ ព្រះអង្គពញាយ៉ាត (១៤១៧-១៤៦៣) បានលើកតាំងភ្នំពេញ ជាទីក្រុងថ្មី ។ ពីរបីឆ្នាំក្រោយមកព្រះអង្គតាំងរាជធានីមានឮឈ្មោះថា ជាទីមានជ័យ គឺជានាមដំបូងបង្អស់នៃក្រុងឧដុង្គ ដែលក្នុងសម័យនោះហៅថា បន្ទាយឮជ័យគឺក្រុងឧដុង្គឮជ័យ ។ ព្រះរាជធានី ភ្នំពេញវិលវិញនៅក្នុងសម័យអាណានិគមបារាំង ។*

*ចំណេរកាលតមកទើបព្រះរាជធានីនេះប្រែ នាមថាក្រុងឧដុង្គមានជ័យ វិញ ។ ឧដុង្គមានជ័យ ជារាជធានីចាស់ នៅក្នុង ខេត្តកំពង់ស្ពឺ (សព្វថ្ងៃនេះ ) ។*

*រាជធានីឧដុង្គធ្លាប់មានព្រះមហាក្សត្រគង់នៅចំនួន ៣៦ព្រះអង្គ ចាប់តាំង ពី គ.ស១៤១៧ ដល់ គ.ស ១៨៦៣ ។ ឧដុង្គស្ថិតនៅចម្ងាយប្រមាណជា៤០គីឡូម៉ែត្រភាគពាយព្យ និងឧត្តរនៃរាជធានីភ្នំពេញក្នុងស្រុកពញាឮ ខេត្តកណ្ដាល ។ ឧដុង្គមានចំណុច៣ធំៗ ៖*

*១-ស្រុកកំពង់ហ្លួង មានផែកប៉ាល់ហ្លួង ។ អ្នកស្រុក ភាគ ច្រើនប្រកបមុខរបរ ជាជាងប្រាក់ ជាងមាស និងជាងស្ពាន់ ។*

*២-វត្តរាំងចាស់ ដែលមានព្រះបដិមាជំនាន់ដើម ។*

*៣-ភ្នំឧដុង្គ, ទីតាំងចេតិយស្តេចខ្មែរ, ហៅ ភ្នំព្រះរាជទ្រព្យ ។ ជាមួយគ្នានេះមានព្រះវិហារព្រះពុទ្ធសាសនាដែលអ្នកស្រុកហៅថាព្រះវិហារអដ្ឋរស្ស ខ្ពស់ ត្រដែត ស្ថិតនៅប៉ែកកខាងត្បូង។ ព្រះវិហារនេះបែរមុខទៅរកទិសខាងជើង ខុសប្លែកពីព្រះវិហារនៅតាមទីវត្តអារាមទាំងអស់ ដែលបែរមុខទៅទិសខាងកើត ។ ការដែលព្រះវិហារនេះ បែរមុខទៅទិសខាងជើងបែបនេះគឺមានជាប់ទាក់ទងទៅនឹងរឿងព្រេងនិទានផងដែរ ។*

*បានជាហៅថាព្រះវិហារអដ្ឋរស្ស[២] បែបនេះ ក៏ព្រោះតែព្រះវិហារនោះមានតម្កល់ព្រះពុទ្ធបដិមា១អង្គដ៏ធំអស្ចារ្យមានកម្ពស់១៨ហត្ថហើយ ។ ពាក្យថា «អដ្ឋរស្ស» ជាភាសាបាលី គឺ១៨នេះ ឯង ។ សព្វថ្ងៃនេះព្រះវិហារអដ្ឋរស្សកំពុងត្រូវបានជួសជុលមិនទាន់រួចរាល់នៅឡើយ ។ ក្រៅពីនេះមានព្រះចេតិយធំៗចំនួន៣ដែលហៅថា ព្រះចេតិយត្រ័យត្រឹង្សតម្កល់ព្រះអដ្ឋិធាតុព្រះមហាក្សត្រខ្មែរ រួមមាន ព្រះបរមរាជានុកោដិព្រះបាទសម្ដេច ព្រះស៊ីសុវត្ថិ ,ព្រះបរមកោដិព្រះបាទសម្ដេចព្រះអង្គឌួង និងព្រះ បាទ ស្រីសូរិយោពណ៌ ។*

 


ថ្ងៃ១៩ធ្នូ ២០០២ ព្រះករុណាព្រះបាទសម្ដេចព្រះនរោត្តម សីហនុ ព្រះបរមរតនកោដ្ឋ (រូបថត) បាន ដង្ហែព្រះសរីរធាតុពី ព្រះសក្យមុនីចេតិយភ្នំពេញនៅ មុខ gare រទេះភ្លើង ទៅដម្កល់នៅ ព្រះមហាសក្យមុនីចេតិយនៅភ្នំឧដុង្គ ឬ ភ្នំព្រះរាជ ទ្រព្យ ។

 

សព្វថ្ងៃភ្នំឧដុង្គជា **បូជនីយដ្ឋាន ព្រះសក្យមុនីចេតិយ។**

បូជនីយេសក៍ Pèlerin, អ្នកស្វះស្វែងរកទីកន្លែងដែលគួរគោរពបូជា, នាំគ្នាធ្វើដំណើរទោះ

១-នមស្ការបូជនីយដ្ឋានតម្កល់ព្រះសរីរធាតុនៃព្រះសម្មាសម្ពុទ្ធ ។ នៅជិតនោះមានព្រះពុទ្ធបដិមា តូចៗជាង៣ពាន់អង្គ ដែលប្រជាជនខ្មែរយើងទាំងទីជិតទីឆ្ងាយតែងទៅ គោរពបូជា សុំសេចក្ដីសុខចម្រុងចម្រើនរាល់ថ្ងៃ ។

២-កន្លែងសក្ការបូជាជាច្រើនកន្លែងទៀតផងដែរ ដូចជា គុហារព្រះគោ ព្រះកែវ អ្នកតាដំបងដែកជាដើម ។ល។

៣-ព្រះចេតិយតូចធំដែលបញ្ចុះព្រះអដ្ឋិព្រះញាតិវង្សានុវង្ស ។



ខាងឆ្វេងដៃជិតព្រះសក្យមុនីចេតិយ យើងឃើញមានមានព្រះចេតិយ ធំៗ ២នៅក្បែរគ្នានោះគឺ

-ចេតិយខាងជើងមានឆ្ងាក់ រូបដំរី លេចក្បាលចេញ ឡើង ប៉ុន ដំរី មែនទែន គេហៅថា "ចេតិយសាមពាន់" ត្រូវបានកសាង ឡើងតាំង ពី គ្រិស្តសករាជ ១៦២៣ ដោយព្រះបាទ ជ័យជេដ្ឋា(១៦១៨-១៦២៥) ដើម្បីបញ្ចុះព្រះបរមអដ្ឋិនៃ ព្រះបាទស្រីសុរិយោពណ៌ ជាព្រះវរបិតា ។ (ចម្លាក់ក្បាលដំរីព័ទ្ធជុំវិញចំនួន៣២ ហើយក៏មានចារឹកអក្សរ១ផ្ទាំងនៅខាងមុខ ថា ព.ស២១៦៦ មហាសករាជ ១៥៤៥។)

-ចេតិយខាងត្បូង ជាប់គ្នានោះ កសាងឡើង ក្នុង គ្រិស្ត សករាជ ១៨៩១ ដោយ ព្រះបាទ សម្ដេចព្រះនរោត្តម (១៨៦០-១៩០៤) ដើម្បីបញ្ចុះ ព្រះបរម អដ្ឋិនៃ ព្រះបាទសម្ដេច ព្រះអង្គឌួង(១៨៤៥-១៨៦០) ជាព្រះវរបិតា ។ (មាន ក្បាច់ និងអក្សរចារឹក១ផ្ទាំងនៅខាងមុខនោះផងដែរថា «ព.ស២៤៣៤ មហាសរាជ១៣១៣ ចុល្លសករាជ ១២៥៣ ឆ្នាំថោះត្រីស័ក គ.ស១៨៩១ ។)

-ចុះតាមជណ្ដើរថ្មទៅត្បូងបន្តិច គេនឹងឃើញចេតិយដ៏ធំមួយទៀតដែលជាចេតិយរបស់ ព្រះករុណាព្រះខត្តិយសកោដ្ឋ ព្រះបាទសម្ដេចព្រះស៊ីសុវត្ថិ (១៩០៤-១៩២៧) មានក្បូរក្បាច់ ស្អាតបាត នៅ ឡើយ ។ (មានរំលេចដោយចម្លាក់ព្រហ្មមុខ៤នៅលើកំពូលតំណាង ឲ្យព្រហ្មវិហារធម៌ ។)

-ចេតិយធំៗ ទាំង៣ ស្ថិតលើកំពូល ភ្នំឧត្តុង្គ ជ្រុងខាងជើង ត្រូវបាន គេហៅថាចេតិយត្រៃត្រិង្ស ព្រះបាទសម្ដេចព្រះស៊ីសុវត្ថិ ទ្រង់មានស្នាមព្រះហស្ដយ៉ាង ច្រើនចំពោះប្រទេសជាតិ ។ ព្រះអង្គបានទាមទារ ឲ្យសៀមចុះសិទ្ធិសញ្ញាជាមួយរាជការអាណាព្យាបាលបារាំងប្រគល់ខេត្តបាត់ដំបង សិរីសោភ័ណ និងសៀមរាប មកឲ្យខ្មែរវិញនៅក្នុងឆ្នាំ១៩០៧ ។ ឯ ប្រាសាទ ព្រះវិហារសៀមប្រគល់មកវិញឆ្នាំ១៩៦២ក្នុងរាជកាលសម្ដេច នរោត្តមសីហនុ រូបសំណាកព្រះអង្គត្រូវបានសាងសង់នៅត្រង់ចង្កេះភ្នំដូនពេញ ឬវត្តភ្នំទុកជាទីសក្ការៈ ៕


Références ឯកសារយោង

២) វចនានុក្រមជួនណាត ។

១)សីលប្រាំនិងរឿងនិទានភាគ១ទំព័រ២០ ទេព ប៊ុនថាក់ណា




ទេព ប៊ុនថាក់ណា 01/03/2022









M. Heng Kim - លោក ហេង គឹម

# សេចក្តីរាយការណ៍អង្គប្រជុំ ឌីយ៉ាស្ពរ៉ាខ្មែរ ទី២
# នៅ ថ្ងៃទី ១០ តុលា ២០២១

ឌីយ៉ាស្ពរ៉ាខ្មែរ

## ក . អ្នកចូលរួមប្រជុំ

អ្នកដែលបានចូលមករួមប្រជុំ នៅថ្ងៃនេះ មាន*ចំនួនទាំងអស់ លើស ៧៥ នាក់* មាន *ព្រះសង្ឃ និងគ្រហស្ថ ដែល បានមកពី ប្រភពខុសៗគ្នា គណបក្ស នយោបាយ ប្រឆាំង សមាគម និងបងប្អូនខ្មែរយើងទូទៅ ក្នុងគោលបំណងពិភាក្សាគ្នា បង្កើត ឌីយ៉ាស្ពរ៉ាខ្មែរ* )DIASPORA KHMERE( ដើម្បីរក មធ្យោបាយ ជួយស្រោចស្រង់ប្រទេសជាតិយើងៗ

## ខ . របៀបវារៈ

របៀបវារៈ នៃការប្រជុំនៅថ្ងៃនេះមាន ដូច តទៅៈ

*១- សេចក្តីថ្លែងការស្វាគមន៍ បើកអង្គប្រជុំ*

*២- សន្ទរកថា ព្រះអង្គ* ជិន គេន និង*ព្រះអង្គ យស ហ៊ុត*

*៣- ការពិភាក្សា គ្នា ដើម្បីបង្កើត សមាគម ឌីយ៉ាស្ពរ៉ាខ្មែរ (Diaspora khmère)*

*៤- ផ្សេងៗ*

## <u>សេចក្តីរាយការណ៍</u>

### *១)* សុន្ទរកថា ស្វាគមន៍

លោកស្រី ឌុក សេដ្ឋា បានធ្វើ សុន្ទរកថា ស្វាគមន៍ និង ថ្លែង អំណរ គុណ ដល់ *ព្រះសង្ឃ និង បងប្អូន ទាំងអស់* ដែលមកចូល ប្រជុំក្នុងថ្ងៃនេះ ដែលយកចិត្តទុកដាក់ដល់ ប្រទេសជាតិ មាតុភូមិ យើងៗ

ឌីយ៉ាស្ពរ៉ាខ្មែរ

## ២ (សុន្ទរកថា ព្រះអង្គគ្រូ ឋិន គេន និង ព្រះអង្គ យស ហ៊ុត

ព្រះសង្ឃ ទាំង ពីរអង្គបាន សង្កត់លើ គោលបំណង បង្រួបបង្រួម ខ្មែរ ឱ្យ ចូលរួមគ្នា ដើម្បីឱ្យមានសាមគ្គីជាតិ ចងភ្ជាប់ជាមួយនិងបងប្អូនខ្មែរនៅក្នុងស្រុក ដែល គាត់ កំពុងតែតស៊ូដើម្បី ***ទាមទារ រកយុត្តិធម៌ សមភាព ភាតរភាព ប្រជាធិបតេយ្យ និង បូរណភាពទឹកដីខ្មែរ***។ ដើម្បីឱ្យឧត្តមគតិនេះ បានជោគជ័យជាការចាំបាច់ ខ្មែរយើង ដែលស្រឡាញ់ប្រទេសជាតិ ត្រូវរួបរួមគ្នា ឱ្យកើតជាបាច់មួយ សម្រាប់ពង្រឹង គ្នាទៅវិញទៅមក ដើម្បីការពារស្រុក និង ជួយបងប្អូនខ្មែរយើង ដែលកំពុងតែតស៊ូក្នុងគោលបំណងដូចយើងដែរ។

ព្រះអង្គ យស ហ៊ុត បានសង្កត់លើការចូលរួម បោះឆ្នោត ក្លែងបន្លំ ដោយយកអង្គការ ត្រួតពិនិត្យគ).ជ.ប( ជាឡប់*ឡៃ* នោះ នាំឲ្យតែពន្យារពេល ឱ្យសោកនាដកម្មខ្មែរយើង បន្តទៅទៀតតែប៉ុណ្ណោះ។ ព្រះអង្គ ឋិន គេន បានសម្តែងការសោកស្តាយ ដែលបក្ស និង ក្រុមទាំងអស់មិនបានរៀបចំធ្វើបាតុកម្ម ២៣តុលារួមគ្នា។

## ***៣» ការពិភាក្សា គ្នា ដើម្បីបង្កើត សមាគម ឪយ៉ាស្តូរ៉ាខ្មែរ***

លោក ហេង គឹម បានធ្វើអត្ថាធិប្បាយ រម្លឹក ពីគោលបំណង នៃការ *បង្កើត សមាគម* ***ឪយ៉ាស្តូរ៉ាខ្មែរ បន្ទាប់មក បាន ចាប់ផ្តើម****ពិភាក្សា គ្នា ដើម្បីបង្កើត សមាគម* ***ឪយ៉ាស្តូរ៉ាខ្មែរ ដោយមាន*** *វាគ្មិន ជា ច្រើន នាក់ មានព្រះសង្ឃ និងគ្រហស្ថ បានឲ្យយោបល់ វែកញែក បំភ្លឺ ពីគោលការណ៍នេះ ដែល យើងអាចសង្ខេបបានដូចតទៅនេះ។*

*១) មតិមួយចំនួន ចង់ឲ្យ ប្រកាសបង្កើតឲ្យបានឆាប់រហ័ស ទោះបីជាសមាជិកផ្តើមបង្កើតមិនបាន១០០ នាក់ ក៏ដោយ។*

*២) មតិមួយទៀត ចង់ឲ្យ បាន១០០ នាក់ យ៉ាងតិច មុន នឹង ប្រកាសបង្កើត ។*

ឪយ៉ាស្តូរ៉ាខ្មែរ

*៣) មតិខ្លះទៀត ចង់ឲ្យ ប្រកាសបង្កើតភ្លាមៗនេះ តែត្រូវនាំគ្នា រកសមាជិកផ្ដើមបង្កើត ថ្មី បន្ថែម ឲ្យបានគ្រប់ ១០០ នាក់ ទៅថ្ងៃក្រោយ។*

*៤) វាគ្មិនខ្លះ* ***មាន****សំនួរថា :* ***ឌីយ៉ាស្ពរ៉ាខ្មែរ ជា*** *សមាគមនយោបាយ ឬមិន មែនទេ ? ហើយមានទិសដៅទៅយ៉ាងណា ?*

នៅទីបញ្ចប់ លោក ហេង គឹម បាន ធ្វើសេចក្ដីសង្ខេបដូចតទៅនេះ :

### ក) ទិសដៅ ឌីយ៉ាស្ពរ៉ាខ្មែរ

***ឌីយ៉ាស្ពរ៉ាខ្មែរ ជា****សមាគម មួយ* ក្នុងគោលបំណង បង្រួបបង្រួម សហគម ខ្មែរ នៅក្រៅស្រុកឱ្យចូលរួមគ្នាបង្កើនសាមគ្គីជាតិ ដើម្បីឱ្យកើតជាបាច់មួយ ដែលសម្រាប់ ពង្រឹងជនជាតិយើង ឲ្យចេះជួយគ្នាទៅវិញ ទៅមក ស្រឡាញ់រាប់អានគ្នា ដើម្បីការពារប្រទេសជាតិ មាតុភូមិយើង ***ទាមទារ រកយុត្តិធម៌ សមភាព ភាតរភាព ប្រជាធិបតេយ្យ និង ការពារបូរណភាពទឹកដីខ្មែរ*** ។

យើងនៅស្ងៀម ធ្វើ មិនដឹងមិនឮការប្រកួក ហៅរបស់ ម្ដាយមាតុ ភូមិ យើង នោះមិនបានទេ។ យើងត្រូវតែសាកល្បង ចូលរួមចងក្រងគ្នាម្ដងទៀត ដើម្បីឱ្យបានមាំទាំ តាមរបៀប យុទ្ធ សាស្ត្រថ្មី ជួយជាសម្ភារៈ ឬ ជាគំនិត ដើម្បីគាំ ទ្រការតស៊ូ ខ្មែរ យើងនេះ។ បើមិនដូច្នោះទេ ការតស៊ូ ខ្មែរ យើងសព្វថ្ងៃនេះ មិន អាចមានដំណើរលឿនទៅមុខទេ ហើយជាការសោកស្ដាយដ៏ជ្រាលជ្រៅ ចំពោះ ប្រទេសជាតិ  ដែលយើងនៅឈរ មើលដោយស្ងប់ស្ងៀម ពេលដែលប្រទេសជាតិកំពុងស្លាប់យ៉ាងអាណោចអាធ័មនេះ ។

នៅកណ្ដាលមហាសមុទ្រ បើយើង មិនកម្រើកនៅស្ងៀមច្បាស់ ជា លង់ ទឹក ស្លាប់។ ប៉ុន្តែបើមានសេចក្ដីក្លាហាន ខំហែល នោះប្រហែល ជា មាន សេចក្ដី សង្ឃឹម នឹង មានជីវិតរស់នៅតទៅទៀតខ្លះ។

ឌីយ៉ាស្ពរ៉ាខ្មែរ

## ខ) ពេលណា ត្រូច ប្រកាសបង្កើតឌីយ៉ាស្ពូរ៉ាខ្មែរ ?

ដោយយោលលើយោបល់ វែកញែក បំភ្លឺ ពីវាគ្មិន ទាំងឡាយ លើគោលការណ៍ បង្កើត សមាគម **ឌីយ៉ាស្ពូរ៉ាខ្មែរ** នេះ យើងបាន អនុម័ត ថាចាប់ធ្វើបញ្ជី សមាជិក ផ្ដើមបង្កើត **ឌីយ៉ាស្ពូរ៉ាខ្មែរ** ដោយសុំឲ្យបងប្អូននៅទីប្រជុំនេះ កត់ឈ្មោះចូលបញ្ជី បើបងប្អូនចង់ចូលជាសមាជិកផ្ដើមបង្កើត។ បន្ទាប់មក យើងម្នាក់ៗ ត្រូវខំដើរ ប្រមូល បងប្អូនយើងផ្សេងៗ ទៀតឲ្យមកចូលរួម។

នៅពេល ២ ទៅ ៣ ខែ ទៀត ឬ ពេល ដែលបាន *សមាជិក ចុះ ឈ្មោះ* ១០០ នាក់ ហើយនោះ យើង នឹង រួមប្រជុំគ្នា ជាលើកទី៣ ដើម្បីប្រកាសបង្កើត *សមាគម ឌីយ៉ាស្ពូរ៉ាខ្មែរ នេះតែម្ដង ហើយធ្វើការ ជ្រើសរើស សមាជិក ក្រុម ការ ដឹក នាំរួម (ន.ក្រ.ស) នាក់ ដែល ៥០ មានចំនួន តែង តាំងឡើង ដោយការបោះឆ្នោត ដើម្បីជាលំនឹង ប្រជាធិបតេយ្យ ក្នុងការ សម្រេច មតិ របស់ ឌីយ៉ាស្ពូរ៉ា តាមសម្លេង រួម គ្រប់មជ្ឈដ្ឋានខ្មែរ ។ លើកលែងតែ ប្រធាន និង អនុប្រធាន គឺ យើង ស្នើសុំ ព្រះអង្គគ្រូ ងិន កេន និង ព្រះអង្គ យស ហ៊ុត ឲ្យធ្វើជា ប្រធាន និង អនុប្រធាន របស់សមាគម ឌីយ៉ាស្ពូរ៉ាខ្មែរ ដែលនឹងរៀបចំ តាម រចនាសម្ព័ន្ធ ក្រុមដឹកនាំខាង ក្រោមនេះ។*

## គ) បញ្ជីសមាជិក ផ្ដើមបង្កើតសមាគម ឌីយ៉ាស្ពូរ៉ាខ្មែរ

*ព្រះសង្ឃ និង បងប្អូន ទាំងអស់* ដែលមកចូល ប្រជុំក្នុងថ្ងៃនេះ បាន*កត់ឈ្មោះចូល* បញ្ជីជា *សមាជិកផ្ដើមបង្កើតសមាគម ឌីយ៉ាស្ពូរ៉ាខ្មែរ* មានចំនួន *៦០នាក់។*

## គ) រចនាសម្ព័ន្ធ ក្រុមដឹកនាំឌីយ៉ាស្ពរ៉ា(DIASPORA)




*ស.ន.ក្រ.* = សមាជិក ***ក្រុមដឹកនាំរួម***

## ៤) ផ្សេងៗ

បងប្អូនយើងខាង *គណបក្សនយោបាយ ឬ សមាគម* បានឆ្លៀតឱកាស នេះ ដើម្បីជូនដំណឹង ពីការ រៀបចំធ្វើ កិច្ចព្រមព្រៀង ទីក្រុង ប៉ារីស ថ្ងៃ ទី២៣ តុលា មានដូចត ទៅ :

១) ក្រុមលោក Sok Sophat, លោក TEP Monorom

សូមនិមន្ត-អញ្ជើញបងប្អូនរួមជាតិ រាល់និន្នាការ ចូលរួមកិច្ចធ្វើ **បាតុកម្ម** រំលឹកខួប ៣០ឆ្នាំ នៃកិច្ចព្រមព្រៀងទីក្រុងប៉ារីស **នៅ ថ្ងៃទី ២៣ តុលា នៅ** Place de la République 75011 Paris ។ Métro : station République, Ligne 3-5-8-9-11

ឌីយ៉ាស្ពរ៉ាខ្មែរ

ទំព័រ 5 / ៦

ISSN : 1168-6847
Dépôt légal : 1er semestre 2022

Président, Vénérable Ngin Phèn
Secrétaire Général Heng Kim

Responsable de la publication : Mme Ung Daravichet Chai

Secrétaire de la publication : Mme Khin Ravie

Membres : Vénérable Pich Samon

M. Ann Tay Kim, M. Michel Chai Sirivuddh – Mme Douc Sétha

Dr. Ngy Hok – Tep Bounthakna - M. Thong Phan

Avec la collaboration des membres et des amis de l'A.S.B.K.

Pagode Bodhivansa – 101 Boulevard de la République – 77420 Champs-sur-Marne
Téléphone : 01 60 06 44 98